**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០២២/០៤/២០០៩ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៩

# ជម្រាបមក

**ឯកឧត្តម ផន ចន្ថា** អតីតតំណាងរាស្ត្រ

**<u>កម្មវត្ថុ</u>** : សំណើបកស្រាយសំណួរមួយចំនួនដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ

**<u>យោង</u>** : លិខិតរបស់ឯកឧតម ផន ចន្ថា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩

-ចំណារលេខ ១៨៨ រស ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩ របស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា បញ្ជូនមកប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យ និងសម្រេចបកស្រាយតាមការគួរ

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០០៩ ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលសំណើរបស់ឯកឧត្តមយកមកពិនិត្យរួចហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពុំអាចលើកយកសំណើសុំបកស្រាយសំណួររបស់ឯកឧត្តមមកពិភាក្សា បានឡើយ ពីព្រោះសំណើរនេះមិនចូលក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានចែងក្នុងមាត្រា ១៣៦ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៥ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ ក្រុមប្រឹក្សាធម្មនុញ្ញ។

សូមឯកឧត្តមទទួលនូវការរាប់អានអំពីខ្ញុំ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**